**ភ្នំពេញ** – គណៈប្រតិភូរួមគ្នាមួយដឹកនាំដោយ **ឯកឧត្តម វង សូត** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងធ្វើដំណើរទៅទស្សនកិច្ចរោងចក្រកាត់ដេរ និងពាណិជ្ជកម្មផ្សេងៗនៅខេត្ត Dongguan ប្រទេសចិន នៅថ្ងៃនេះទី២៨ ខែឧសភា ឆ្នាំ២០១១ រយៈពេលបួនថ្ងៃ (ពីថ្ងៃទី២៨-៣១ ខែឧសភា ឆ្នាំ២០១១) ដើម្បីសិក្សាពីស្ថានភាពនិងការអភិវឌ្ឍន៍នៃទីផ្សារការងារ និង សហប្រតិបត្តិការល្អប្រសើរនៅកន្លែងការងាររបស់ប្រទេសចិន ។



ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ឈរនៅទីប្រាំរាប់ពីស្តាំ) លោក គង់ សាង អនុប្រធានទីមួយនៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងសមាជិកប្រតិភូ

**ឯកឧត្តម វង សូត** (ឈរនៅទីប្រាំរាប់ពីស្តាំក្នុងរូបថត) និងសមាជិកប្រាំបីរូបទៀតរួមមាន **ឯកឧត្តម សេង សាក្កា** អគ្គនាយក លោក **អ៊ិន ខេមរា** ប្រធាននាយកដ្ឋានអធិការកិច្ចការងារ លោក **កុយ ទេពដារារុធ** ប្រធាននាយកដ្ឋានវិវាទការងារ លោក **ម៉ែន សុចិត្រ** ប្រធានខុទ្ទកាល័យរដ្ឋមន្ត្រី និង លោក **គង់ សាង** អនុប្រធានទីមួយនៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា លោក **អាប៊ីត តាន់** អគ្គហិរញ្ញិក និងឧកញ៉ា **ណាង សុធី** និង លោក **លី តេកហេង** នាយកប្រតិបត្តិនៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា នឹងមានកិច្ចប្រជុំនិងកិច្ចពិភាក្សាផ្ទាល់ជាមួយបណ្តាអ្នកវិនិយោគផ្ទាល់បរទេសទាំងក្នុង និងក្រៅតំបន់នៅក្នុងតំបន់ឧស្សាហកម្មដែលល្បីល្បាញនៅភាគខាងត្បូងនៃប្រទេសចិន។ មេរៀនទាំងអស់ដែលរៀនពីដំណើរទស្សនកិច្ចនេះ នឹងជាតម្លៃបន្ថែមមួយសម្រាប់ការធ្វើឲ្យប្រសើរឡើងនៃទំនាក់ទំនងការងារឧស្សាហកម្មរបស់កម្ពុជា និងសម្រាប់ការធ្វើឲ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការការងារល្អរបស់យើង។

លោក **គង់ សាង** បានថ្លែងមុនពេលចាកចេញថា៖ «យើងនឹងមានឱកាសឃើញ និងរៀនពីការអភិវឌ្ឍន៍នៃពាណិជ្ជកម្ម និងការវិនិយោគរបស់ចិន។ យើងក៏រំពឹងឃើញការអភិវឌ្ឍន៍ធនធានមនុស្សល្អ និងរបៀបដែលកិច្ចសហប្រតិបត្តិការនិងទំនាក់ទំនងល្អនៅកន្លែងការងារត្រូវបានធ្វើឡើង»។

សមាគមរោងចក្រកាត់ដេរនៅកម្ពុជា កាលពីពេលមុន ធ្លាប់បានរៀបចំដំណើរទស្សនកិច្ចស្រដៀងគ្នានេះដែរ ដោយមានការចូលរួមពីតំណាងក្រសួងផ្សេងៗដើម្បីស្វែងរកការអនុវត្តល្អបំផុតនិងវិធីជំរុញលើកស្ទួយបរិយាកាសវិនិយោគរបស់កម្ពុជា។

លោក **កុយ ទេពដារារ៉ុជ** ប្រធាននាយកដ្ឋានដោះស្រាយវិវាទការងារ ដែលកាលពីមុនធ្លាប់បានចូលរួមដំណើរទស្សនកិច្ច និងឥឡូវកំពុងចូលរួមដំណើរទស្សនកិច្ចជាលើកទីពីរ រំពឹងថាលោកនឹងឃើញភាពផ្លាស់ប្តូរផ្សេងៗនៅក្នុងការអភិវឌ្ឍន៍ និងស្ថានភាពការងារក្នុងប្រទេសចិន។ លោកបានបន្តថា៖ «ខ្ញុំមានទំនុកចិត្តថា មេរៀនដែលរៀនបាននឹងជួយជានាឲ្យមាននូវពាណិជ្ជកម្មមួយដែលសន្តិភាពនិងទទួលបានផ្លែផ្កានៅក្នុងប្រទេសកម្ពុជា»។

**ព័ត៌មានសមាគមរោងចក្រកាត់ដេរនៅកម្ពុជា**